## ខចែខ & លក្ខខណ្ឌនៃការផ្ទេរប្រាក់

១. មូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារទាំងអស់ នឹងត្រូវបានចេញ ដោយគូសបញ្ជាក់ថា "មិនអាចជួញដូរបាន" និងមានសុពលភាពរយៈពេលប្រាំមួយ (០៦) ខែ គិតចាប់ពីថ្ងៃចេញ។

២. ការបើកសាច់ប្រាក់ ឬ ការទូទាត់នៃឧបករណ៍ធនាគារ នឹងត្រូវបានចុះឥណទានទៅក្នុងគណនីដែលពាក់ព័ន្ធ។ ការលើកលែងណាមួយ ត្រូវមានការអនុញ្ញាតពីធនាគារ។

៣. ការស្នើសុំផ្ទេរប្រាក់ ធ្វើឡើងតាមរយៈមូលប្បទានប័ត្រ នឹងចាប់មានសុពលភាព នៅពេលដែលមូលប្បទានប័ត្រត្រូវបានទូទាត់។

៤. ធនាគារ (រួមទាំងសាខាទាំងអស់) មិនទទួលខុសត្រូវចំពោះការពន្យាពេល ការខូចខាត ឬ ការខាតបង់ដែលបណ្ដាលមកពីក្រឹត្យ ច្បាប់ ឬបទបញ្ជារបស់រដ្ឋាភិបាលណាមួយ ឬភ្នាក់ងាររបស់ពួកគេ ឬបទបញ្ជារបស់អាជ្ញាធរដែលមានសមត្ថកិច្ច (មិនថានៅកម្ពុជា ឬនៅកន្លែងណាមួយ) ឬ មូលហេតុផ្សេងៗទៀតដែលមិនអាចគ្រប់គ្រងបានដោយធនាគារ សាខាធនាគារ ភ្នាក់ងារ ឬធនាគារទំនាក់ទំនង។

៥. ធនាគារត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សាខា ធនាគារទំនាក់ទំនង ឬភ្នាក់ងាររបស់ខ្លួន ឬភ្នាក់ងារផ្សេងទៀតសម្រាប់ធ្វើប្រតិបត្តិការទូទាត់ឧបករណ៍ធនាគារ ឬផ្ទេរប្រាក់ក្នុងនាមអតិថិជន។

៦. ការផ្ទេរប្រាក់តាមតេឡេក្រាហ្វិក ត្រូវបានបញ្ជូនតាមរយៈទូរលេខ តេឡេក្រាម ឬទូរសារ ឬតាមរយៈបណ្ដាញផ្សេងទៀត ដោយមានលេខកូដ ឬការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ស្របតាមលក្ខខណ្ឌតម្រូវ និងជាហានិភ័យផ្ទាល់ខ្លួនទាំងស្រុងរបស់អ្នកស្នើ។ ធនាគារ ឬសាខា ធនាគារទំនាក់ទំនង និងភ្នាក់ងាររបស់ខ្លួន មិនទទួលខុសត្រូវចំពោះលទ្ធផល ឬការខាតបង់ដែលអាចកើតមានឡើង ដោយសារភាពរអាក់រអួល ការខកខានមិនបានធ្វើកំហុសឆ្គង ការបកស្រាយខុស ការខូចខាតធ្ងន់ធ្ងរ ការខាតបង់ ឬ ការយឺតយ៉ាវក្នុងការផ្ទេរ ឬ ការពន្យាពេលក្នុងការទទួលប្រាក់ដោយអ្នកទទួល។

៧. ទោះបីជាធនាគារនឹងព្យាយាមបញ្ជូនពាក្យស្នើសុំផ្ទេរប្រាក់តាមតេឡេក្រាហ្វិក នៅក្នុងថ្ងៃធ្វើការតែមួយ ឬក្នុងថ្ងៃធ្វើការបន្ទាប់ ធនាគារ ឬ ភ្នាក់ងាររបស់ធនាគារមិនទទួលខុសត្រូវចំពោះការពន្យាពេលក្នុងការទូទាត់ ប្រសិនបើប្រតិបត្តិការត្រូវបានពន្យាពេលដោយសារភ្នាក់ងារស្ថិតនៅក្នុងតំបន់ដែលមានម៉ោងខុសគ្នា ឬការពន្យាពេលដែលបណ្ដាលមកពីថ្ងៃឈប់សម្រាកនៅក្នុងប្រទេសដទៃទៀត។

៨. ខណៈដែលធនាគារនឹងព្យាយាមអនុវត្តបញ្ជាទូទាត់នៅក្នុងថ្ងៃតែមួយ ឬថ្ងៃធ្វើការបន្ទាប់ (អាស្រ័យលើម៉ោងទទួល) នៅពេលដែលទទួលបានបញ្ជាទូទាត់ពីគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត ធនាគារត្រូវបានផ្ដល់ពេលវេលាសម្រាប់ធ្វើការបញ្ជាក់ ឬធ្វើការសាកសួរបន្ថែមពីធនាគារដែលផ្ទេរ ឬ ភាគីពាក់ព័ន្ធផ្សេងទៀត ប្រសិនបើបញ្ជាផ្ទេរប្រាក់មិនត្រឹមត្រូវតាមលំដាប់លំដោយ ឬមិនពេញលេញ ឬប្រសិនបើមានភាពមិនស្របគ្នាណាមួយ។

៩. ប្រសិនបើសាច់ប្រាក់ស្ថិតនៅជាមួយធនាគារនៅឡើយ ការបង្វិលប្រាក់ជូនអតិថិជនវិញដោយធនាគារ សម្រាប់ចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រធនាគារ ឧបករណ៍ធនាគារ ឬ ការផ្ទេរប្រាក់តាមតេឡេក្រាហ្វិក នឹងត្រូវបានធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ធនាគារ។ ធនាគារនឹងកាត់សោហ៊ុយ ការប្រាក់ ថ្លៃសេវា និងថ្លៃចំណាយផ្សេងៗដែលកើតមានឡើង។ ការបង្វិលប្រាក់ជូនវិញ ត្រូវអនុលោមទៅតាមខចែង និងលក្ខខណ្ឌនៃការផ្ទេរប្រាក់ដែលកំណត់ដោយធនាគារ ដែលអាចកែប្រែពីពេលមួយទៅពេលមួយ។ ប្រសិនបើទឹកប្រាក់ជារូបិយប័ណ្ណបរទេស អត្រាប្តូរប្រាក់ដែលមានសុពលភាព (អត្រាទិញចូល) ក្នុងថ្ងៃបង្វិល ត្រូវបានយកមកប្រើប្រាស់។ ក៏ប៉ុន្តែ ការបង្វិលប្រាក់ជូនវិញនេះ ត្រូវយោងទៅតាមការរឹតត្បិត ដែលអាចកំណត់ដោយធនាគារពីពេលមួយទៅពេលមួយ។ មូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារ ត្រូវតែប្រគល់ឲ្យធនាគារវិញ មុននឹងការទូទាត់ណាមួយត្រូវបានធ្វើឡើង។

១០. ប្រសិនបើ មូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារបានបាត់ ត្រូវបានគេលួច ឬ ត្រូវបានបំផ្លាញ អ្នកស្នើអាចស្នើសុំឲ្យចេញ មូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារជំនួសវិញ។ ក៏ប៉ុន្តែ អ្នកស្នើត្រូវផ្តល់ធនាគារនូវលិខិតជួសជុលសំណង ការពារធនាគារឲ្យរួចផុតពីការខាតបង់ ឬការទទួលខុសត្រូវលើមូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារដែលបានបាត់បង់ ត្រូវបានលួច ឬត្រូវបានបំផ្លាញ ឬឯកសារផ្សេងទៀតដែលអាចតម្រូវដោយធនាគារ។ អ្នកស្នើ ត្រូវរ៉ាប់រងថ្លៃសេវាសម្រាប់ការចេញមូលប្បទានប័ត្រធនាគារ ឬ ឧបករណ៍ធនាគារថ្មី ហើយធនាគារអាចកំណត់ថ្លៃសេវាសម្រាប់ការចេញមូលប្បទានប័ត្រ ឬឧបករណ៍ជំនួស ដែលអាចកែប្រែពីពេលមួយទៅពេលមួយ។

១១. អ្នកស្នើត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗទៅសាខា អំពីការមិនទទួលបានប្រាក់ដោយអ្នកទទួលផល។ នៅពេលដែលទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកស្នើ ធនាគារត្រូវពិនិត្យបណ្តឹងរបស់អ្នកស្នើ និងធ្វើការស៊ើបអង្កេត និងការកែតម្រូវចាំបាច់ផ្សេងៗ ប្រសិនបើមាន។ ថ្លៃចំណាយទាំងអស់ដែលកើតមានឡើងទាក់ទងនឹងនីតិវិធីខាងលើ ជាបន្ទុករបស់អ្នកស្នើ។

១២. ថ្លៃសេវាទាំងអស់នៅក្រៅប្រទេសកម្ពុជា ជាបន្ទុករបស់អ្នកទទួលផល លើកលែងតែមានការបញ្ជាផ្ទុយពីនេះ។

១៣. ធនាគារមានសិទ្ធបង្ហាញព័ត៌មាននៅក្នុងដំណើរការអាជីវកម្មធម្មតារបស់ខ្លួន ទាក់ទងនឹងគណនី ឬទំនាក់ទំនងរបស់អ្នកស្នើ ដោយមិនចាំបាច់មានការយល់ព្រមជាមុនពីអ្នកស្នើឡើយ៖

ក. ទៅឲ្យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ សម្រាប់គោលបំណងស៊ើបអង្កេត។

ខ. សម្រាប់ ឬទាក់ទងជាមួយសកម្មភាព ឬនីតិវិធីដែលត្រូវបានធ្វើឡើងសម្រាប់គោលបំណងប្រមូលមកវិញនូវប្រាក់ដែលជំពាក់ និងដល់ពេលទូទាត់ដោយអ្នកស្នើឲ្យទៅធនាគារ។

គ. ឲ្យទៅអាជ្ញាធរ ឬស្ថាប័នបង្កើតដោយធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរផ្សេងទៀតដែលមានយុត្តាធិការលើធនាគារ។និង

ឃ. ដូចដែលបានបង្គាប់ ឬស្នើសុំដោយតុលាការ។

១៤. ធនាគាររក្សាសិទ្ធិក្នុងការបញ្ចេញព័ត៌មានទាំងឡាយទៅសាខា ទីស្នាក់ការកណ្តាលរបស់ខ្លួន ឬរដ្ឋាភិបាលសម្រាប់គោលបំណងរាយការណ៍តាមបទប្បញ្ញត្តិ តាមការតម្រូវ។

១៥. ធនាគារមានសិទ្ធិ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនចាំបាច់បញ្ជាក់មូលហេតុ ធ្វើការបដិសេធ និង/ឬ លុបចោល និង/ឬ មិនទទួលយកពាក្យស្នើសុំមូលប្បទានប័ត្រធនាគារ ឧបករណ៍ធនាគារ និង/ឬ ធ្វើការផ្ទេរប្រាក់តាមតេឡេក្រាហ្វិក ប្រសិនបើធនាគារសង្ស័យថា ផលសម្រាប់ធ្វើការទូទាត់ត្រូវទទួលបានដោយខុសច្បាប់ និង/ឬ ទឹកប្រាក់ត្រូវបានផ្ទេរសម្រាប់គោលបំណងខុសច្បាប់ និងក្នុងករណីដែលធនាគារមិនពេញចិត្តជាមួយព័ត៌មានណាមួយ និង/ឬ ព័ត៌មានលម្អិតដែលផ្តល់ដោយអ្នកស្នើសម្រាប់គាំទ្រពាក្យស្នើសុំ។

១៦. ធនាគារ ទិញ/លក់ ក្រដាសប្រាក់/រូបិយប័ណ្ណ ក្នុងអត្រាប្តូរប្រាក់ប្រចាំថ្ងៃធម្មតា ចេញផ្សាយដោយធនាគារ។ ការលក់រូបិយប័ណ្ណ នឹងត្រូវកំណត់ដោយនិងអាស្រ័យលើចំនួនទឹកប្រាក់ដែលមាននៅពេលធ្វើប្រតិបត្តិការ។